# វត្តព្រះឥន្ទ្រកោសីយ៍

វត្តព្រះឥន្ទ្រកោសីយ៍ ឬជាទូទៅអ្នកសៀមរាបហៅ "វត្តលើ" ស្ថិតនៅភូមិទ្រាំង ក្រុងសៀមរាប ទល់មុខអភិរក្សអង្គរ ខាងកើតស្ទឹងសៀមរាប។ ដែលអ្នកសៀមរាបហៅ "វត្តលើ" ពីព្រោះកាលជំនាន់ដើម នៅក្នុងខេត្តសៀមរាបវត្តនេះនៅផ្នែកខាងលើគេ បើគិតតាមខ្សែទឹកហូរនៃស្ទឹងសៀមរាបដែលហូរចុះពីភ្នំគូលែនហូរទៅទន្លេសាប។ ការហៅឈ្មោះទីតាំងដោយគិតទៅតាមចរន្តទឹកស្ទឹងហូររបៀបនេះជារឿងធម្មតា។ ឧទាហរណ៍នៅខេត្តសៀមរាបមានឈ្មោះផ្សារលើ ផ្សារក្រោម មានឈ្មោះវត្តពោធិលើ វត្តពោធិក្រោម។ល។ ខេត្តដទៃទៀតដែលមានចរន្តទឹកស្ទឹងបែបនេះ ពោលគឺមានឈ្មោះដូចគ្នាដែរ។

នៅក្នុងបរិវេណវត្តនេះមានប្រាសាទសាងអំពីឥដ្ឋ អ្នកស្រាវជ្រាវបារាំងបានឱ្យសន្និដ្ឋានថាប្រាសាទនេះមានតួប៉មបី ប៉ុន្តែជាក់ស្តែងយើងឃើញសព្វថ្ងៃមានតួប៉មតែពីរប៉ុណ្ណោះ។ នៅក្នុងសិលាចារឹកនៃប្រាសាទនេះផ្ទាល់មានចារឈ្មោះថា "**ទ្វិជេន្ទ្របុរ**" (**ក្រុងទ្វិជេន្ទ្រ**) ថ្វីត្បិតថាពិបាកប្រែន័យ "**ទ្វិជេន្ទ្រ**" ឱ្យត្រូវពិតប្រាកដក្តីអ្នកស្រាវជ្រាវខ្លះសន្និដ្ឋានថាអាចមានន័យ "ក្រុងដែលមានប្រាសាទពីរ?" ដែលសមស្របទៅនឹងបរិបទ នៃប្រាសាទនេះផ្ទាល់ដែលមានតួពីរ។ ឬឈ្មោះនេះអាចមានន័យផ្សេងទៀត?។

យោងតាមសិលាចារឹក ប្រាសាទនេះសាងនៅក្នុងសតវត្សទី១០។ នៅស៊ុមទ្វារនៃប្រាសាទនេះមានសិលាចារឹកពីរផ្ទាំងដែលមានចុះបញ្ជីលេខ K.262 ជាភាសាខ្មែរ និង K.263 ជាភាសាសំស្ក្រឹតនិងខ្មែរ។ សិលាចារឹកនិយាយអំពីការស្ថាបនាប្រាសាទ ដោយមានសរសេរឈ្មោះ "ទ្វិជេន្ទ្របុរ" ដែលជាឈ្មោះទីតាំងបុរាណ ពោលគឺសព្វថ្ងៃស្ថិតនៅចំទីតាំងនៃវត្តព្រះឥន្ទ្រកោសីយ៍នេះ។ លោក សឺដែស (Goerge Cœdès) សន្និដ្ឋានថាសិលាចារឹក K.262 ដែលចារទាក់ទងនឹងឈ្មោះ "ទ្វិជេន្ទ្របុរ" សាងនៅគ.ស.៩៦៨ ពោល គឺចូលដល់ដើមរាជ្យរបស់ព្រះបាទជ័យវរ្ម័នទី៥ (គ្រងរាជ្យពី គ.ស.៩៦៨ ~គ.ស.១០០២)។ ទាក់ទងនឹងកាលបរិច្ឆេទគ.ស.៩៦៨ ដែលចារនៅលើសិលាចារឹកនៃប្រាសាទនេះ ក៏មានចារនៅ

អត្ថបទដោយ៖ លោក ញឹម សុធារិទ្ធ

សិលាចារឹកនៃប្រាសាទមួយទៀតដែលមានឈ្មោះដើម “Madhuvana” បើជាភាសាខ្មែរថា “ព្រៃឃ្មុំ" សាងនៅឆ្នាំ៩៦៨ ដោយព្រាហ្មណ៍ឈ្មោះ **ទិវាករភដ្ត** (Divākarabhaṭṭa)។ ព្រាហ្មណ៍នោះបានរៀបអភិសេកជាមួយព្រះនាង **ឥន្ទ្រលក្ស្មី** ជាបុត្រីរបស់ព្រះបាទរាជេន្ទ្រវរ្ម័ន (គ្រងរាជ្យពីគ.ស.៩៤៤ ដល់គ.ស.៩៦៨)។

នៅតួប៉មខាងត្បូងមាននៅសល់ផ្តែរច្បាស់ល្អអាចមើលដឹងអំពីទេព និងទេពកថាខ្លះ។ នៅផ្នែកខាងក្រោមនៃផ្តែរ ថ្វីត្បិតនៅផ្នែកកណ្តាលជ្រុះបាត់ចម្លាក់ទេពក្តី ប៉ុន្តែនៅមានសល់រូបដំរីដែលអាចឱ្យយើងដឹងថាទេពនេះជាព្រះឥន្ទ្រ។ នៅផ្នែកខាងលើផ្តែរមានចម្លាក់ទេពផ្សេងៗ ប៉ុន្តែអ្វីដែលគួរឱ្យកត់សម្គាល់នោះ គឺមានបង្ហាញអំពីទេពកថាក្នុងរឿងកូរសមុទ្រទឹកដោះ ដែលជារឿងមានការពេញនិយមណាស់នៅសម័យអង្គរ។

ចំពោះឈ្មោះដែលគេហៅសព្វថ្ងៃថា “**ព្រះឥន្ទ្រកោសីយ៍**” គឺជាឈ្មោះរបស់ព្រះឥន្ទ្រនៅក្នុងព្រះពុទ្ធសាសនាថេរវាទ។ "**កោសីយ៍**" មានន័យដូចនឹងពាក្យសំស្ក្រឹត "**កោសវន្ត** Kośavant" ជាឈ្មោះរបស់ព្រះឥន្ទ្រមួយទៀត ហើយដែលមានន័យថា "ដោតវាសនា ឬសំណាង"។ ឈ្មោះ “**កោសីយ៍**” នេះឃើញមានច្រើននៅក្នុងអត្ថបទសម័យកណ្តាល ជាពិសេសនៅក្នុងកំណាព្យល្បើកអង្គរវត្តដែលគេតែងនៅសតវត្សទី១៧។ ដូច្នេះឈ្មោះ “**ព្រះឥន្ទ្រកោសីយ៍**” ដែលហៅសព្វថ្ងៃនេះគឺសំខាន់ ព្រោះអាចឱ្យយើងដឹងអំពីទំនាក់ទំនងរបស់វត្តនេះទៅនឹងសម័យកណ្តាល (ស.វទី១៤ ដល់ស.វទី១៩)។

អត្ថបទដោយ៖ លោក ញឹម សុធារិទ្ធ



ប្រាសាទព្រះឥន្ទ្រកោសីយ៍ មើលពីខាងកើត





សិលាចារឹកនៅស៊ុមទ្វារ K. 262

អត្ថបទដោយ៖ លោក ញ៉ឹម សុធារិទ្ធ

## ផ្តែរនៅតួប៉មខាងត្បូង





អត្ថបទដោយ៖ លោក ញឹម សុធារិទ្ធ